# ឯកសារពិភាក្សាស្តីពី

# យុទ្ធសាស្ត្រដើម្បីបង្កើនអត្រាគង់វង្សរបស់សិស្សនៅបឋមសិក្សា

សូមគោរព ឯកឧត្តមប្រធាន ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ

ជាបឋម ខ្ញុំសូមសំដែងនូវសេចក្តីសោមនស្សរីករាយជាពន្លឹកចំពោះឯកឧត្តម លោកជំទាវទាំងអស់ ដែលបានជួយគាំទ្រដល់ការអភិវឌ្ឍន៏វិស័យអប់រំរបស់ប្រទេសកម្ពុជា។ ក្នុងឱកាសនេះខ្ញុំមានកិត្តិយសនឹងជម្រាបជូនដោយសង្ខេបអំពីវឌ្ឍនភាព និងបញ្ហាប្រឈមមួយចំនួនដែលវិស័យអប់រំកំពុងជួបប្រទះ ទាក់ទងទៅនឹងសូចនាករពិនិត្យតាមដានរួមគ្នា (JMIs) ព្រមទាំងបង្ហាញជូនពីការប្តេជ្ញាចិត្តមួយចំនួនដើម្បីកែលំអសូចនាករទាំងនោះ ។

សូចនាករពិនិត្យតាមដានរួមគ្នាទីមួយដែលផ្តោតលើការចូលរៀន មានការរីកចម្រើនយ៉ាងច្រើន ដែលធ្វើឱ្យយើងសង្ឃឹមថា គោលដៅសូចនាករពិនិត្យតាមដានរួមគ្នាមួយនេះនឹងអាចសម្រេចបាន។ កាលពីទសវត្សរ៍មុនសិស្សនៅបឋមសិក្សាមានចំនួនតិចជាងពីរលាននាក់ ប៉ុន្តែសព្វថ្ងៃនេះ ចំនួនសិស្សបានកើនឡើងច្រើនជាងពីរលានប្រាំមួយសែននាក់។ ជាលទ្ធផល យើងឃើញថាអត្រាពិតនៃការសិក្សាបានកើនឡើងពី៧៨% ទៅដល់៩២% ក្នុងរយៈពេលជិត១០ឆ្នាំកន្លងមក។ យោងទៅតាមតួលេខនេះ ការសម្រេចបានសកលកម្មការអប់រំបឋមសិក្សានៅជិត១០ឆ្នាំខាងមុខទៀតអាចសម្រេចបាន ប៉ុន្តែវាទាមទារឱ្យយើងផ្តោតអារម្មណ៏ថែមទៀតទៅលើបញ្ហាការបោះបង់ការសិក្សានៅបឋមសិក្សា ។

តាមនិយមន័យ សិស្សបោះបង់ការសិក្សាគឺជាសិស្សដែលមិនបានបញ្ចប់ការសិក្សា។ ជាការពិត សិស្សដែលបោះបង់ការសិក្សាមួយចំនួនបានវិលត្រឡប់ចូលសាលារៀនវិញ ឬពួកគេអាចត្រូវបានផ្តល់ឱ្យនូវជម្រើសទទួលការអប់រំក្រៅប្រព័ន្ធ ដែលបានរៀបចំឡើងសម្រាប់ឱ្យពួកគេបញ្ចប់កម្មវិធីសិក្សានៅបឋមសិក្សា។ ដោយមានការជួយជ្រោមជ្រែងពីសហគមន៏អ្នកផ្តល់ជំនួយនិងអង្គការក្រៅរដ្ឋាភិបាល រាជរដ្ឋាភិបាលបានបង្កើតកម្មវិធីចូលរៀនឡើងវិញ សម្រាប់ជួយសិស្សដែលបោះបង់ការសិក្សាឱ្យបានបញ្ចប់គ្រប់កម្រិតសិក្សានៃបឋមសិក្សា។ ប៉ុន្តែតាមរយៈ ទិន្នន័យរបស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ចំនួនសិស្សបោះបង់ការសិក្សាមានចំនួនច្រើននៅឡើយ។ សម្រាប់ប្រទេសកម្ពុជា ដែលត្រូវបានគេចាត់ទុកថាកំពុងស្ថិតនៅលើមាគ៌ាដ៏ត្រឹមត្រូវមួយនោះ ត្រូវតែស្វែងរកវិធីសាស្ត្របន្ថែមមួយចំនួនទៀត ក្នុងការរក្សាសិស្សឱ្យនៅបន្តការសិក្សា និងកាត់បន្ថយការបោះបង់ការសិក្សាឱ្យបានច្រើន។

ចំណែកសូចនាករពិនិត្យតាមដានរួមគ្នាទីពីរ ដែលផ្តោតលើអត្រាគង់វង្សរបស់សិស្សនៅបឋមសិក្សានោះ ក្រសួងទទួលស្គាល់ថានឹងមានការបញ្ហាប្រឈមជាច្រើនទៀត។ ជាង១០ឆ្នាំកន្លងមក ការកើនឡើងនៃចំណូលផលទុនជាតិសរុប (GDP per capita) បង្ហាញពីភាពស្របគ្នាទៅនឹងការកើនឡើងការចូលរៀនរបស់សិស្សនៅបឋមសិក្សា។ ខណៈដែលការចូលរៀននៅបឋមសិក្សាបានកើនឡើង អត្រាគង់វង្សក៏បានកើនឡើងយ៉ាងខ្លាំងដែរ គឺពី៣១,៣% នៅឆ្នាំ ១៩៩៧ ទៅដល់៥១,១%ក្នុងឆ្នាំ២០០១។ អត្រាគង់វង្សនេះបានស្ថិតនៅក្នុងកម្រិតថេរមួយប្រហែល៥០% ចាប់ពីឆ្នាំ ២០០១ ដល់ឆ្នាំ២០០៥។ តើអ្វីអាចពន្យល់ពីនិន្នាការនេះបាន? រាជរដ្ឋាភិបាលកម្ពុជាទទួលបានជោគជ័យក្នុងយុទ្ធសាស្ត្រ **ឈ្នះ-ឈ្នះ** របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ដែលឈានទៅដល់ការពង្រីកវិសាលភាពគ្របដណ្តប់របស់ការអប់រំបឋមសិក្សា ជាពិសេសនៅតាមតំបន់ជួបការលំបាក ដូចជាតំបន់ដែលគ្រប់គ្រងដោយអតីតខ្មែរក្រហម តំបន់ព្រំដែន តំបន់ចំការមីន និងតំបន់អតីតសមរភូមិ។ ការបង្កើនសេវាអប់រំឱ្យដល់តំបន់ជួបការលំបាកទាំងនោះមានន័យថា ឥឡូវនេះ យើងបានបង្កើនការយកចិត្តទុកដាក់កាន់តែខ្លាំងទៅដល់កុមារជួបការលំបាក និងកុមារដែលពីមុនមកយើងមិនបានយកចិត្តទុកដាក់ ដែលពួកគេទាំងនោះភាគច្រើនបោះបង់ការសិក្សាឬរៀនត្រួតថ្នាក់។ ដូច្នេះក្រសួងអប់រំ យុវជន និងកីឡានឹងបន្តអនុវត្តវិធានការកាត់បន្ថយការបោះបង់ការសិក្សា និងរៀនត្រួតថ្នាក់របស់សិស្ស ជាពិសេសក្នុងចំណោមកុមារដែលជួបការលំបាក។អត្រាបោះបង់ការសិក្សានៅបឋមសិក្សាបានធ្លាក់ចុះពី១៥%ក្នុងឆ្នាំ១៩៩៧ មកនៅត្រឹម១២%នៅឆ្នាំ២០០៥ ទោះជាយ៉ាងណាក៏ដោយ អត្រានេះនៅមានកម្រិតខ្ពស់នៅឡើយដែលចាំបាច់ត្រូវកាត់បន្ថយថែមទៀត។

ឯកឧត្តម ភ្ញៀវកិត្តិយស អស់លោក លោកស្រីជាទីគោរព ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើការពិភាក្សាគ្នាយ៉ាងល្អិតល្អន់ក្នុងចំណោមនាយកដ្ឋានជំនាញដែលពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ដោយបានដាក់ចេញជាអនុសាសន៍ ដែលជាគោលបំណងរួមសម្រាប់បង្កើនអត្រាគង់វង្សរបស់សិស្សនៅបឋមសិក្សាដែលរួមមាន :

**ក. អភិវឌ្ឍសៀវភៅសិក្សាគោលៈ** ផ្តល់សៀវភៅសិក្សាគោលឱ្យដល់សិស្ស និងគ្រូតាមកាលកំណត់។

**ខ. ផ្តល់ការគាំទ្រដល់សាលាជួបការលំបាក :** សង់ផ្ទះគ្រូបង្រៀននិងអន្តេវាសិកដ្ឋានសម្រាប់សិស្ស។

**គ. កាត់បន្ថយចំនួនសាលារៀនមិនគ្រប់កម្រិតៈ** សង់បន្ទប់រៀនបន្ថែម បង្គន់អនាម័យ និងទឹកស្អាត អនុវត្តថ្នាក់គួបនៅតំបន់មួយចំនួននិងធ្វើឱ្យទៅជាសាលាគ្រប់កម្រិតនៅតាមតំបន់ដែលមានប្រភពសិស្ស។

**ឃ. អនុវត្តវិមជ្ឈការកាលវិភាគ :** អនុវត្តជាក់ស្តែងតាមមូលដ្ឋាន និងរដូវកាល។

**ង. ស្វ័យវាយតម្លៃសាលារៀន និងការពិនិត្យតាមដានៈ** បំប៉នសមត្ថភាពនាយកអំពីការបំពេញបែបបទវាយ តម្លៃ និងពិនិត្យតាមដានលើការបំពេញការងាររៀន និងបង្រៀន។

**ច. កែលំអបទបញ្ជាផ្ទៃក្នុងៈ** ពិនិត្យនិងកែសម្រួលឡើងវិញបទបញ្ជាផ្ទៃក្នុង ពិនិត្យនិងកែលំអការប្រឡងឡើងថ្នាក់។

ឆ. **ផ្តោតការយកចិត្តទុកដាក់លើកត្តាគ្រូបង្រៀន:** ជ្រើសរើសគ្រូបង្រៀនតាមមូលដ្ឋាន ដំឡើងប្រាក់ឧបត្ថម្ភជូនគ្រូនៅតំបន់ដាច់ស្រយាលនិងតំបន់ជួបការលំបាក ។

ជ. **កែលំអការងារស្ថិតិ:** ការគ្រប់គ្រងស្ថិតិសិស្សត្រូវមានភាពច្បាស់លាស់ ត្រឹមត្រូវដោយស្មារតីទទួលខុសត្រូវខ្ពស់នៅគ្រប់លំដាប់ថ្នាក់ ។

ក្រសួងមានក្តីសោមនស្សរីករាយក្នុងការទទួលបាននូវការគាំទ្រដ៏សប្បុរសបន្ថែមទៀត ដល់ការអនុវត្តយុទ្ធសាស្ត្រដែលបានលើកឡើង សំដៅកែលំអស្ថានភាពរបស់វិស័យអប់រំនាពេលបច្ចុប្បន្នអោយកាន់តែល្អប្រសើរ។ ក្រសួងសូមស្វាគមន៍នូវរាល់ការផ្តល់អនុសាសន៍ និងសំណូមពរទាំងឡាយ។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់របស់ ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិទាំងអស់ ។